# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១២

## ជប៉ុនផ្តល់ ៧៤០,៥៩៧ ដុល្លារអាមេរិកដើម្បីបង្កើនប្រសិទ្ធភាពបោសសម្អាតសំណល់ជាតផ្ទុះក្រោយសង្គ្រាមក្នុងខេត្តតាកែវ(ជំហ៊ានទី២)



ក្រោមគ្រោងការណ៍នៃជំនួយឥតសំណងសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុនរដ្ឋាភិបាលជប៉ុនបានផ្តល់ទឹកប្រាក់សរុបចំនួន ￥៥៩,៩៨៨,៣៥៧ស្មើនឹង៧៤០,៥៩៧ដុល្លាអាមេរិកដល់អង្គការសកម្មភាពកំចាត់មីនជប៉ុន(JMAS)។កិច្ចសន្យាផ្តល់ជំនួយត្រូវបានចុះហត្ថលេខានាថ្ងៃនេះនៅស្ថានទូតជប៉ុនដោយឯកឧត្តម គូរ៉ូគី ម៉ាសាហ៊្វូមី ឯកគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និងលោក តានីហ្សាវ៉ា យ៉ាស៊ូយូគិ ប្រធានតំណាងអង្គការJMASដើម្បីអនុវត្តគម្រោងបង្កើនប្រសិទ្ធភាពបោសសម្អាតសំណល់ជាតិផ្ទុះក្រោយសង្គ្រាមនៅខេត្តតាកែវ។



តាមរយៈគម្រោងនេះ JMASនឹងផ្តល់ជំនួយផ្នែកបច្ចេកទេសដល់មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា(CMAC)ដើម្បីបង្កើនសកម្មភាពបោសសម្អាតសំណល់ជាតិផ្ទុះក្រោយសង្គ្រាមក្នុងប្រទេសកម្ពុជា។ ជាងនេះទៅទៀត JMASនឹងប្រើប្រាស់ក្រុមបោសសម្អាតអាវុធជាតិផ្ទុះចំនួន៥ក្រុមដើម្បីធ្វើសហប្រតិបត្តិការជាមួយCMACក្នុងខេត្តតាកែវ កំពង់ឆ្នាំង សៀមរាប កំពង់ធំ និងពោធិ៍សាត់ដែលប្រជាជននៅតែបន្តរងគ្រោះដោយសារសំណល់ជាតិផ្ទុះពីសង្គ្រាម។ JMASក៏នឹងប្រើប្រាស់ក្រុមកាត់បន្ថយគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌមិនទាន់ផ្ទុះតាមសហគមន៍ដើម្បីប្រមូលពត៌មានអំពីសំណល់ជាតិផ្ទុះក្រោយសង្គ្រាម និងដើម្បីអនុវត្តសកម្មភាពផ្សព្វផ្សាយដល់ប្រជាជនមូលដ្ឋានឲ្យយល់ដឹងអំពីគ្រោះថ្នាក់នៃសំណល់ជាតិផ្ទុះពីសង្គ្រាម និងជៀសវាងឧបទ្ទវហេតុដោយសារការធ្វេសប្រហែសចំពោះសំណល់ជាតិផ្ទុះក្រោយសង្គ្រាម។

កម្មវិធីជំនួយឥតសំណងសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុនបានចាប់ផ្តើមនៅប្រទេសកម្ពុជាតាំងពីឆ្នាំ២០០២ដើម្បីគាំទ្រសកម្មភាពរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុនក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីជួយដល់ការអភិវឌ្ឍន៍ និងស្តាបនាប្រទេសកម្ពុជាឡើងវិញនៅតាមកំរិតមូលដ្ឋាន។ ចាប់តាំងពីឆ្នាំ២០០២

មក រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាជាង១៧លានដុល្លាអាមេរិកដល់គម្រោងចំនួន៦៧គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុនដែលផ្តោតសំខាន់ទៅលើវិស័យអប់រំនៅកម្រិតមូលដ្ឋាន វិស័យសុខាភិបាលនិងសកម្មភាពបោសសំអាតមីន។គម្រោងរបស់អង្គការJMASនេះគឺជាគម្រោងទី៣តាមរយៈគ្រោងការណ៍នៃជំនួយនេះសម្រាប់ឆ្នាំសារពើពន្ធឆ្នាំ២០១២របស់ជប៉ុន(មេសា២០១២ដល់មិនា២០១៣)។



---

*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*

*ទូរសព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៤-៣៣០*

*អ៊ីមែល:* *eco.jpn@.pp.mofa.go.jp*

*គេហទំព័រ: http://www.kh.emb-japan.go.jp*